FACT SHEET

(Cambodian - Public Charge, California Edition) 11/1/00

សម្រាប់រដ្ឋកាលីហ្វូរញ៉ា
សេចក្ដីណែនាំត្រួសៗពី " Public Charge "
នឹងការទទួលជំនួយសារធារណៈ (ជំនួយពីរដ្ឋ)

ការណែនាំត្រួសៗនេះ ជាការបញ្ជាក់ឲ្យដឹងពីការទទួលជំនួយពីរដ្ឋ នៅសហរដ្ឋអាមេរិកនឹងការទាក់ទង ឬ មិនទាក់ទងដល់ស្ថានភាពនៃជនអន្ដោប្រវេសន៍នៅក្នុង "បន្ទុកសាធារណៈ" ទៅតាមច្បាប់អន្ដោរប្រវេសន៍ ។
" Public Charge " គឺជាជនដែលការទទួលខុសត្រូវ ជាបន្ទុកដល់រដ្ឋាភិបាល ។

- **ជនអន្ដោរប្រវេសន៍ ដែលដាក់ពាក្យសុំជានិវាសនដ្ឋានស្របច្បាប់ "LPRs" (ដែលពុំទាន់មានត្រកូនកាតនៅឡើយ)**

  - ជនអន្ដោរប្រវេសន៍មិនអាចចាត់ថាជា"បន្ទុកសាធារណៈ" ក្នុងការប្រើ :

    - **HEALTH CARE BENEFITS:** ជំនួយខាងថែទាំសុខភាពរួមទាំង មេឌី-កាល់ (medi-Cal) គ្រួសារសុខភាពល្អ (Healthy Families – ហ៊ីលធីហ្ហ្ហ្ហ្ហ) ការថែទាំស្ត្រីមានផ្ទៃពោះ ឬ ការព្យាបាលដោយឥតគិតថ្លៃ ឬ ដោយយកតម្លៃតិចនៅតាមមណ្ឌលព្យាបាលរោគ ឬ គ្រិះស្ថានផ្សេងៗទៀត លើកលែងតែកន្លែងដែលព្យាបាលវ៉ីយ៉ូ ដូចជាគ្រិះស្ថាន ថែទាំជនជរាពិការ ឬ មណ្ឌលដែលស្រដៀងគ្នា ។

    - **FOOD PROGRAMS :** កម្មវិធីផ្ដល់ម្ហូបដូចជាប័ណ្ណទិញម្ហូប **WIC** (កម្មវិធីពិសេសក្នុងការផ្ដល់ម្ហូបបន្ថែមដល់ស្ត្រី ទារក និងកូនក្មេង) ការផ្ដល់ម្ហូបតាមសាលារៀន ឬ ជំនួយម្ហូបផ្សេងៗទៀត ។

- **OTHER PROGRAMS THAT DO NOT GIVE CASH** : កម្មវិធីជំនួយដ៏ទៃទៀតដែលមិនឲ្យជាប្រាក់ដូចជា កម្មវិធីផ្ទះសាធារណៈ ជំនួយថែរទាំក្មេង ជំនួយថាមពល (ប្រេងកំដៅ-ភ្លើង...) ជំនួយពេលមហន្តរាយ កម្មវិធី (Head Start) ដូចជាមត្តេយ្យសាលា ការបង្រៀនការងារផ្សេងៗ ជំនួយសត្តិអារមណ៍ និងឲ្យដំបូន្មាន ។

- **ក្រសួងអន្តោប្រវេសន៍ (INS) និងពិនិត្យជនអន្តោប្រវេសន៍ដែលប្រើកម្មវិធីខាងក្រោមក្នុងការចេញត្រិនកាតឲ្យ ។**
  - **CASH WELFARE,** ប្រាក់ជំនួយ ; (SSI) ប្រាក់ជំនួយបន្ថែម ; (TANF) ប្រាក់ជំនួយបន្តោះអាសន្នដល់គ្រួសារដែលខ្វះខាត ដែលនៅទីនេះគេហៅថា កាល់-ហ្វត "Cal Works" កម្មវិធីប្រាក់ជំនួយដល់ជនអន្តោប្រវេសន៍ (CAPI) និងជំនួយទូរទៅពីរដ្ឋ ។
  - **INSTITUTIONALIZATION,** ការតម្រូវឲ្យនៅមន្ទីរព្យាបាលក្នុងរយៈពេលយូរ ដូចជានៅកន្លែងថែរទាំមនុស្សចាស់និងជនពិការ ឬ កន្លែងមណ្ឌលព្យាបាលរោគត្រសៃប្រសាទដែលតម្រូវឲ្យរដ្ឋាភិបាលចេញប្រាក់កាស ។

សំគាល់ : ក្រសួងអន្តោប្រវេសន៍នឹងមិនចាត់ទុកថាក្រុមគ្រួសារជនអន្តោប្រវេសន៍ដែលទទួលប្រាក់និងរបស់ផ្សេងទៀតជាជំនួយថាជាបន្ទុកដល់រដ្ឋទេ លើកលែងតែជំនួយជាប្រាក់នោះ ជាថវិការតែមួយគត់សំរាប់គាំទ្រគ្រួសារនោះ ។

- **ជនអន្តោប្រវេសន៍ស្របច្បាប់ នៅទីនេះដ៏យូរ ហើយមានត្រិនកាត : L P Rs**

  L P Rs ជនអន្តោប្រវេសន៍ជំពូកនេះមិនអាចចាត់បង់សិទ្ធិដោយត្រូវគេដកហ្វូតត្រិនកាតទេ ក្នុងលក្ខណៈដែលគេឬក្រុមគ្រួសារគេប្រើជំនួយខាងក្រោម :
  - ជំនួយថែរទាំសុខភាព កម្មវិធីជំនួយម្ហូប ឬកម្មវិធីឯទៀតដែលគ្មានប្រើប្រាក់
  - ប្រាក់ជំនួយ វ៉ែលហ្វែរ (មើលកំណត់ខាងក្រោម ក្នុងការអនុគ្រោះ)
  - ការថែរទាំយូរពេលវេលា (មើលកំណត់ខាងក្រោម ក្នុងការអនុគ្រោះ)

សំគាល់:

- ជនអន្តោប្រវេសន៍ស្របច្បាប់ដែលនៅទីនេះយូរមកហើយ អាចត្រូវក្រសួងអន្តោប្រវេសន៍សាកសួរ ថាគាត់នៅក្នុងបន្ទុករដ្ឋឬទេនៅពេលដែលអ្នកនោះចូលមកកាន់សហរដ្ឋវិញក្នុងលក្ខណៈដែលគេចាកចេញពីស្រុកនេះលើសពី ៦ខែរហើយ ការទទួលប្រាក់ជំនួយវែលហ្វែរ នឹងការថែរទាំដ៏យូរពេលអាចត្រូវដោះស្រាយ។

- ក្នុងករណីខ្ទះ ជនស្របច្បាប់ ដែលយកប្រាក់វែលហ្វែរនឹងប្រើការថែទាំយូរពេលក្នុងកំឡុង ៥ឆ្នាំដំបូងដែលគាត់មកនៅស្រុកនេះ (ដោយសារពិការ ឬ មានជម្ងឺ) មុនពេលដែលគាត់មកកាន់ សហរដ្ឋ អាចត្រូវគេបញ្ជូនត្រឡប់ទៅវិញ ដោយសារគាត់ជាបន្ទុកដល់រដ្ឋ ។

- **ជនភ្ជៀសខ្ទួន នឹងអ្នកដែលរដ្ឋអនុញ្ញាតឲ្យជ្រកកោននៅទីនេះ** អាចប្រើជំនួយផ្សេងៗ តាំងពីប្រាក់វែលហ្វែរ ការថែរទាំជម្ងឺ ជំនួយបណ្ណ៍ម្ហូប នឹងជំនួយផ្សេងៗ ទៀតដោយមិនមានការប៉ះពាល់ដល់ការទទួលគ្រិនកាត ។

- **ការធានាបងប្អូន** ជនជាតិអាមេរិកាំងនឹងអ្នករស់នៅស្របច្បាប់ អាចធានាបងប្អូនបាន ទោះបីគេទទួលជំនួយផ្សេងៗ ដូចជាប្រាក់វែលហ្វែរ ជំនួយខាងថែរទាំសុខភាព ជំនួយម្ហូបអាហារ នឹងជំនួយផ្សេងៗទៀតដែលមិនឲ្យជាប្រាក់ក៏ដោយ ។ ក៏ប៉ុន្តែ អ្នកធានា(នឹងអ្នកជួយធានា)ត្រូវមានធ្វើរសំបុត្រធានារាប់រង (Affidavit of Support) បញ្ជាក់ថាគេមានប្រាក់គ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ដល់បងប្អូននោះ ដោយមានចំនួន ១២៥ ភាគរយនៃកំពស់ ភាព ក្រីក្រ ។

- **ការចូលសញ្ជាតិអាមេរិកាំង** - **LPRs** អ្នករស់នៅស្របច្បាប់ (ដែលមានគ្រិនកាត) ដែលទទួលជំនួយពីរដ្ឋតាមច្បាប់ មានសិទ្ធិគ្រប់គ្រាន់ក្នុងការសុំចូលសញ្ជាតិអាមេរិកាំង។

ត្រូវការពត៌មានថែមទៀត ?

ជាពត៌មានថែមទៀតអំពី "បន្ទុកសាធារណៈ" **" Public Charge "**
សូមមើលក្រសួងអន្តោប្រវេសន៍ INS Web site : w w w. ins.usdoj.gov សម្រាប់កំ
ណត់បញ្ជាក់ នឹង ចំឡើយចំពោះសំនួរផ្សេងៗ ។ ពត៌មានអាចផ្តល់ជូនជាភាសាផ្សេងៗ
ក្នុងតារាង "កិច្ចការសាធារណៈ" (Public Affairs) ។

ដើម្បីជាពត៌មានថែមទៀត ក្នុងការចុះឈ្មោះក្នុងកម្មវិធីជំនួយនេះ
សូមអញ្ជើញទាក់ទងនឹងក្រសួងទទួលខុសត្រូវរបស់ (រដ្ឋាភិបាល) សហពន្ធ័ រដ្ឋ នឹង
តាមដំបន់ ។ ខាងក្រោមនេះជាទីទាក់ទងសំខាន់ៗ :

សម្រាប់ Healthy Families: 1-800-880 5305. (ទូរសព្ទ័មិនគិតលុយ)
សម្រាប់ហ្វូតស្តែម Food Stamps: 1-800-221 5689. (ទូរសព្ទ័មិនគិតលុយ)
សម្រាប់ WIC : 1-888-942 9675. (ទូរសព្ទ័មិនគិតលុយ)
សម្រាប់ កាល់-ហ្វត មេឌី-កាល់ Calworks, Medi-Cal នឹងជំនួយផ្សេងៗទៀត
សូមទាក់ទងនឹងក្រសួង វែលហ្វែរប្រចាំស្រុក (County Welfare Department).

* នេះជាអត្ថបទដែលបានបកប្រែរ អត្ថបទផ្ទូវការមានជាភាសារអង្វេស ។